ប្រើ ClearType សម្រាប់ពុម្ពអក្សរលើអេក្រង់ម៉ូនីទ័ររបស់កុំព្យូទ័រ Laptop អេក្រង់សំប៉ែតនៃម៉ូនីទ័រកុំព្យូទ័រ

1. ចុចលើ START menu
2. ចុចលើ Control Panel
3. ចុចលើ Appearance and Themes
4. ចុចលើ Display
5. ក្នុងបង្អួច Display Properties ចុចយកបន្ទះ Appearance tab
6. ចុចលើប៊ូតុង Effects...
7. ផែកយកប្រអប់ ☑ Use the following method to smooth edges of screen fonts
8. ចុចលើព្រួញនៅខាងស្តាំប្រអប់រួចជ្រើសយក ClearType
9. ចុច OK
10. ចុច OK
11. ចុចបិទបង្អួចAppearance and Themes ត្រង់សញ្ញា X នៅខាងលើនិងខាងស្តាំដៃ



សទ្ទានុក្រមកុំព្យូទ័រ

**ActiveX** គឺជាសំណុំបច្ចេកវិជ្ជាដែលអនុញ្ញាតឲ្យសមាសភាគជាច្រើននៃសហ្វវែរធ្វើអន្តរកម្មរវាងគ្នាក្នុងបរិស្ថាននៃបណ្តាញមួយ អន្តរកម្មទាំងនោះកើតឡើងដោយគ្មានជាប់ពាក់ព័ន្ធជាមួយនឹងភាសាដែលត្រូវបានគេយកទៅប្រើសម្រាប់បង្កើតសមាសភាគទាំងឡាយនោះទេ។

**Internet Protocol (IP)** គឺជាពិធីសារ(protocol)អាចបញ្ជូនបាននៅក្នុងស៊េរីពិធីសារTCP/IP ដែលទទួល ខុសត្រូវក្នុងការរៀបចំសំបុត្រ(addressing) បញ្ជូន(routing) និងបំបែក ជា បំណែក (fragmentation) រួចផ្គុំឡើងវិញ(reassembly)នៃកញ្ចប់ IP។

**Protocol** គឺជាសំណុំនៃក្បួនខ្នាតនិងការសន្មត់(convention)សម្រាប់ផ្ញើរពត៌មានលើបណ្តាញមួយ។ ក្បួននេះគ្រប់គ្រងលើខ្លឹមសារ(content) ទម្រង់(format) ការកំណត់ពេល(timing) លំដាប់លំដោយ (sequences) និងការត្រួតត្រាកំហុសនៃសារ(message)ដែលផ្លាស់ប្តូរគ្នាក្នុងចំណោមឧបករណ៍ ទាំងឡាយរបស់បណ្តាញ(network)។

**Transmission Control Protocol/Internet Protocol (TCP/IP)** គឺជាសំណុំនៃពិធីសាររបស់បណ្តាញ ត្រូវបានគេប្រើជាទូទៅលើប្រព័ន្ធអ៊ីនធឺណែតដែលផ្តល់ទំនាក់ទំនងទៅវិញទៅមកលើបណ្តាញកុំព្យូទ័រជាច្រើនភ្ជាប់ចូលគ្នាជាមួយស្ថាបត្យកម្ម(architecture)ផ្នែករឹង(hardware)និងប្រព័ន្ធប្រតិបត្តិការ (operating system)នានា។ TCP/IP រាប់បញ្ចូលនូវខ្នាតគំរូ(standards)ជាច្រើនដែលប្រាប់ពីរបៀបដែលកុំព្យូទ័រទាំងឡាយធ្វើការទាក់ទងគ្នានិងរាប់បញ្ចូលនូវការសន្មត់នានាសម្រាប់ភ្ជាប់បណ្តាញនិងចរាចរបញ្ជូន (routing traffic)។

**Kernel** គឺជាគ្រឿងសំខាន់(core)នៃស្ថាបត្យកម្មតំរៀបជាជាន់ថ្នាក់(layered)ដែលគ្រប់គ្រងប្រតិបត្តិការមូលដ្ឋានស្ទើរតែទាំងអស់របស់ប្រព័ន្ធប្រតិបត្តិការ(operating systems)និងគ្រឿងដំណើរការ(processor)របស់កុំព្យូទ័រ។ Kernel ដាក់កាលវិភាគឲ្យបំណែក(components)ផ្សេងៗនៃកូដប្រតិបត្តិការ(ឬហៅថាអំបោះ threads)សម្រាប់គ្រឿងដំណើរការរក្សាទុកវាឲ្យជាប់រវល់តាមតែអាចធ្វើបានហើយវាក៏សម្របសម្រួលគ្រឿងដំណើរការជាច្រើនដើម្បីធ្វើឲ្យការប្រតិបត្តិមានប្រសិទ្ធភាពខ្ពស់។ Kernel ក៏សម្របសម្រួលសកម្មភាពនានាក្នុងចំណោមអនុសមាសភាគ (subsystem)ក្នុងលំដាប់ប្រតិបត្តិដូចជា(executive-level )ហើយវាក៏ចាត់ចែងការលើកលែងផ្នែករឹងមួយចំនួន(hardware exceptions)និងមុខងារពឹងលើផ្នែករឹងដទៃទៀត (hardware-dependent functions)។ Kernel ធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងស្រទាប់អរូបីយ៍នៃផ្នែករឹង (hardware abstraction layer)។

## ប្រព័ន្ធឯកសារប្រភេទ NTFS

គឺជាប្រព័ន្ធឯកសារដ៏ទំនើបមួយដែលផ្តល់លទ្ធផលការងារ(performance) សន្តិសុខ(security) ភាពជឿជាក់ (reliability) និងចំណុចពិសេស(features)ជាច្រើនទៀតដែលមិនឃើញមាននៅក្នុងជំនាន់ប្រព័ន្ធឯកសារប្រភេទFAT។ ឧទាហរណ៍ NTFSធានាស្ថិរភាព(consistency)របស់ចំណុះ(volume)ដោយប្រើបច្ចេកទេសកត់ត្រាទុក(logging) និងយកមកប្រើវិញ(recovery)នូវសកម្មភាពទាក់ទងមានខ្នាតគំរូ (standard transactions)។ បើប្រព័ន្ធមួយមិនដំណើរការ NTFSប្រើពត៌មាន ក្នុងឯកសារកត់ទុក(log file) និងក្នុងចំណុចត្រួតពិនិត្យ(checkpoints)ដើម្បីស្រង់មកវិញ(restore)នូវស្ថិរភាពរបស់ប្រព័ន្ធឯកសារ។ ក្នុង Windows 2000និងWindows XP, NTFSក៏ផ្តល់ផងដែរនូវចំណុចល្អៗជាច្រើនដូចជាការអនុញ្ញាតិឲ្យប្រើឯកសារនិងក្រប(folder)របស់វា ការបង្កើតអក្សរសម្ងាត់(encryption) ការរៀបចំកូតារបស់ឌីស(disc quota) និងការសង្កត់ឲ្យណែន(compression)នូវឯកសារ។

## Firewall

គឺជាបន្សំរវាងផ្នែករឹងនិងផ្នែកទន់(software)ដែលផ្តល់នូវប្រព័ន្ធសុវត្ថិភាពមួយ ជាទូទៅវាការពារកុំឲ្យកុំព្យូទ័រមកពីខាងក្រៅចូលមកក្នុងបណ្តាញខាងក្នុងឬចូលក្នុងប្រព័ន្ធអ៊ីនធឺណែត។ Firewall ទប់ស្កាត់ទំនាក់ទំនងដោយផ្ទាល់រវាងបណ្តាញនិងកុំព្យូទ័រខាងក្រៅដោយបញ្ជូនទំនាក់ទំនងតាមរយៈកុំព្យូទ័របម្រើជាតំណាង (proxy server)ក្រៅបណ្តាញ។ កុំព្យូទ័របម្រើជាតំណាងកំណត់ថាតើមានសុវត្ថិភាពឬទេបើអនុញ្ញាតឲ្យឯកសារមួយចូលមកក្នុងបណ្តាញ។ Firewall ក៏មានឈ្មោះមួយទៀតហៅថារបងមានសុវត្ថិភាព(security-edge gateway)។

## TCP/IP

អានថាធីស៊ីភីអាយភីជាពាក្យកាត់របស់Transmission Control Protocol/Internet Protocol (ពិធីសារត្រួតត្រាការបញ្ជូនឬពិធីសារសម្រាប់អ៊ីនធឺណែត) វាគឺជាបណ្តុំនៃពិធីសារទំនាក់ទំនងដែលគេប្រើសម្រាប់ភ្ជាប់កុំព្យូទ័រជាភ្ញៀវ(hosts)ទាំងឡាយនៅលើប្រព័ន្ធអ៊ីនធឺណែត។ TCP/IPប្រើប្រាស់ពិធីសារជាច្រើន ក្នុងនោះពិធីសារចម្បងជាងគេគឺ TCP និង IP ។ TCP/IP ត្រូវបានគេសាងសង់ឡើងនៅក្នុងប្រព័ន្ធប្រតិបត្តិការយូនិច (UNIX)ហើយត្រូវបានប្រើដោយប្រព័ន្ធអ៊ីនធឺណែត ដែលជាការធ្វើឲ្យTCP/IPក្លាយទៅជាខ្នាតគំរូពិតប្រាកដសម្រាប់បញ្ជូនទិន្នន័យលើបណ្តាញកុំព្យូទ័រនានា។ សូម្បីប្រព័ន្ធប្រតិបត្តិការសម្រាប់បណ្តាញកុំព្យូទ័រដែលមានពិធីសាររបស់ខ្លួនវានោះ(ឧទាហរណ៍Netware)ក៏គាំទ្រTCP/IPដែរ។

## Cache

សម្រាប់DNSនិងWINS គឺជាការរក្សាទុកពត៌មានជាមូលដ្ឋាននូវកំណត់ត្រាខាងធនធានសម្រាប់ឈ្មោះកុំព្យូទ័រជាភ្ញៀវចូលមកពីទីឆ្ងាយដែលបានដោះស្រាយរួចហើយ។ ជាទូទៅវាត្រូវបានគេសាងសង់ឡើងជាបញ្ជីសំណួរសម្រាប់កុំព្យូទ័រនិងឈ្មោះកុំព្យូទ័រដែលបានដោះស្រាយរួច។ វាក៏ជួយធ្វើឲ្យប្រសើរបំផុតនូវពេលវេលាទាមទារឲ្យដោះស្រាយដោយឈ្មោះកុំព្យូទ័រដែលត្រូវបានសួរនាំ។

អានថាcash គឺជាយន្តការរក្សាទុកទិន្នន័យដ៏មានល្បឿនលឿន។ វាអាចជាផ្នែកមួយនៃប្រព័ន្ធចងចាំចម្បងដែលត្រូវបានរក្សាទុកឬអាចជាឧបករណ៍ឯករាជ្យមួយសម្រាប់រក្សាទុកទិន្នន័យដ៏មានល្បឿនលឿន។ ក្នុងកុំព្យូទ័រផ្ទាល់ខ្លួន(personal computers)មានប្រភេទcachingពីរយ៉ាងគឺmemory cachingនិងdisk caching។ Memory caching ឬពេលខ្លះហៅថាcache storeឬRAM cacheជាផ្នែកមួយនៃប្រព័ន្ធចងចាំដែលបង្កើតឡើងដោយhigh-speed static RAM (SRAM)ជាជាងdynamic RAM(DRAM)ដែលដំណើរការយឺតនិងមានតម្លៃថោកជាងហើយត្រូវបានគេប្រើក្នុងប្រព័ន្ធចងចាំចម្បង(main memory)។ Memory cachingមានប្រសិទ្ធភាពពីព្រោះថាកម្មវិធីស្ទើរតែទាំងអស់ចូលទៅយកទិន្នន័យឬការណែនាំដូចៗគ្នាច្រំដែលៗច្រើនដង។ ដោយរក្សាទុកពត៌មាននេះឲ្យបានច្រើនតាមតែអាចធ្វើបាននៅក្នុង(SRAM) ពេលនោះកុំព្យូទ័រជៀសវាងការចូលទៅយកទិន្នន័យក្នុង(DRAM)ដែលដំណើរការយឺត។

## របៀបតំឡើងឌីសរឹងទីពីរនៅក្នុងកុំព្យូទ័ររបស់អ្នក

១ ការរៀបចំ (Preparation)

២ ផែនការសម្រាប់ការតំឡើង (Planning the installation)

៣ ការកំណត់រូបសណ្ឋានរបស់ឌីស (Configuring the drive)

៤ ការតភ្ជាប់ឌីស (Connecting the drive)

៥ ការកំណត់ប្រព័ន្ធគ្រឿងនាំចូលនិងនាំចេញជាមូលដ្ឋាន(Configuring BIOS)

៦ ការបែងចែកបន្ទប់របស់ឌីស (Partitioning the drive)

៧ ការកំណត់ស្ថានភាពឌីសសម្រាប់ប្រើ (Formatting the drive)




## ហេតុផលក្នុងការតំឡើងឌីសទីពីរ

១ អ្នកត្រូវការកន្លែងទំនេររបស់ឌីសរឹងបន្ថែមទៀត

២ អ្នកត្រូវការវាសម្រាប់ចម្លងឯកសារទុកក្នុងគ្រាអាសន្ន

៣ អ្នកត្រូវការបង្កើតប្រព័ន្ធចាប់ដំណើរការពីរ

## ១ ការរៀបចំ

មុនចាប់ផ្តើមការងារ ត្រូវពិនិត្យមើលថាអ្នកមានឧបករណ៍សម្រាប់តំឡើងគ្រប់គ្រាន់នៅក្បែរដៃ(មើលរូប) ក៏ប៉ុន្តែអ្នកមិនចាំបាច់មានឧបករណ៍ទាំងអស់នោះដើម្បីចាប់ផ្តើមការងារទេ។



អ្នកអាចត្រូវការពិលមួយសម្រាប់បំភ្លឺក្នុងទីកន្លែងងងឹត។ 🖫ការសំខាន់អ្នកត្រូវមានឌីសទន់ដែលមានកម្មវិធីសម្រាប់ដំណើរការ(MS-DOS startup disk )។

### របៀបបង្កើត MS-DOS startup disk

☞ក្នុង Windows 98: ចុចStart > Settings > Control Panel ជ្រើសយកបន្ទះ Startup Disk រួចដាក់ឌីសទន់(floppy disk🖬)ដែលនៅទំនេរចូលក្នុងរន្ធរបស់វា រួចចុច Create Disk។

☞ក្នុង Windows XP: ចុចStart > My Computer > ចុចជ្រើសយកឌីសទន់(3½ Floppy🖬) រួចចុចលើ File menu រួចចុច Format ក្នុងFormat options រួចចុច Create an MS-DOS startup disk ដាក់ឌីសទន់នៅទំនេរមួយចូលក្នុងរន្ធរបស់វា រួចចុច Start ។

## ២ ផែនការសម្រាប់ការតំឡើងឌីស

ចំណុចទី១គឺអ្នកចាំបាច់ត្រូវពិនិត្យឲ្យច្បាស់ថាប្រព័ន្ធរបស់អ្នកអាចទទួលយកឌីសរឹងទីពីរឬទេ។ មានបន្ទះមេស្ទើរតែទាំងអស់គាំទ្រIDE channels ពីរ បានន័យថា IDE1 គឺជាprimary channel ចំណែកឯ IDE2គឺជា secondary channel។ បន្ទះមេសម័យទំនើបមួយចំនួនមានឧបករណ៍គ្រប់គ្រងបន្ថែមដែលអនុញ្ញាតឲ្យវាអាចទទួលIDE channelsចំនួន៤។ ប្រដាប់ភ្ជាប់(connectors)អាចប្រើសម្រាប់ភ្ជាប់ATA devicesធ្វើជាឌីសមេ(master drive)មួយនិងឌីសបម្រើ(slave drive)មួយនៅក្នុងប្រព័ន្ធ(channel)និមួយៗ។

ឧបករណ៍អានឌីសអុបទិក(Optical drives)មាន CD-ROM drives និង CD-Writersហើយនិងឧបករណ៍ដែលអាចដកយកចេញបានមួយចំនួនក៏ភ្ជាប់ជាមួយ(removable ATAPI devices)ដែរ ដូច្នេះអ្នកត្រូវប្រាកដថាមានចន្លោះទំនេរមួយសម្រាប់ឌីសរឹង។ បើមិនមានចន្លោះទំនេរទេ អ្នកអាចរកទិញបន្ទះPCI IDE controller host adapter card ។ អ្នកក៏ត្រូវពិនិត្យមើលផងដែរថាតើpower supplyរបស់កុំព្យូទ័រអ្នកមានសមត្ថភាពអាចផ្គត់ផ្គង់ចរន្តឲ្យឌីសរឹងទី២ឬទេ។ បើចាំបាច់ អ្នកអាចជំនួសវាដោយpower supply unit (PSU)ថ្មី។